# រំឭកមេរៀនវិទ្យាសាស្ត្រ

១.តើកុមារទើបកើត អាចទទួលបានថ្នាំបង្ការអ្វីខ្លះ?

ក.របេង ខ.កញ្ច្រឹល គ.ក្អកមាន់ ឃ.តេតាណូស

២.តើមេរោគហិបរស់នៅកន្លែងណា?

ក.ក្នុងមាត់និងច្រមុះ ខ.ច្រមុះនិងបំពង់ក

គ.បំពង់ក និងអណ្ដាត ឃ.បំពង់កនិងក្រពះ

៣.តើមេរោគហិបឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតដូចម្ដេច?

ក.ប្រើប្រាស់សម្ភារៈរួមគ្នា ខ.មូសខ្លាញីខាំ

គ.ការបញ្ចូលឈាម ឃ.និយាយឆ្លើយឆ្លងឬកណ្ដាស់ដាក់គ្នា

៤.តើស្ត្រីមានផ្ទៃពោះត្រូវចាក់ថ្នាំបង្ការជំងឺអ្វី?

ក.ខ្វះគ្រាប់ឈាម ខ.តេតាណូស គ.គ្រុនឈាម ឃ.រលាកស្រោមខួរ

៥.ដើម្បីព្យាបាលជំងឺរាក គេត្រូវធ្វើដូចម្ដេច?

ក.ផឹកទឹកឱ្យបានច្រើន តែហាមបរិភោគ ខ.បរិភោគឱ្យបានច្រើនតែហាមផឹកទឹក

គ.ផឹកផង បរិភោគផងឱ្យបានច្រើន ឃ.ផឹកទឹកឱ្យបានច្រើន

៦.ក្នុងចំណោមជំងឺខាងក្រោម តើជំងឺអ្វីដែលឆ្លងតាមការប្រើប្រាស់ សម្ភារៈរួមគ្នា ឬបរិភោគអាហារគ្មានអនាម័យ?

ក.ថ្លើម ខ.រលាកស្រោមខួរ គ.គ្រុនឈាម ឃ.របេង

៧.តើស្ត្រីមានផ្ទៃពោះ ត្រូវចាក់ថ្នាំបង្ការជំងឺតេតាណូសប៉ុន្មានដងដើម្បីការពារបានពេញមួយជីវិត?

ក.៣ដង ខ.៤ដង គ.៥ដង ឃ.៦ដង

៨.ព្រូនតម្កក់ឆ្លងតាមណា?

ក.មាត់ ខ.ស្បែក គ.ទ្វារលាមក ឃ.ប្រើសម្ភារៈរួមគ្នា

LIVEWORKSHEETS

៩.មេរោគហិបអាចបង្កឱ្យមានជំងឺអ្វីខ្លះ ?

ក.គ្រុនស្វិតដៃជើង　　ខ.ក្អកមាន់　　គ.រលាកថ្លើម　　ឃ.ជំងឺសិបទីសេមី

១០.ចូរដាក់ឈ្មោះពីក្រោមរូបខាងក្រោម។





....................................　　....................................

LIVEWORKSHEETS